ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករគណនេយ្យនិងសវនកម្ម

លេខ ០៥៨/២៤ ន. គ. ស/សរ.ជ.ពា.

# សេចក្តីជូនដំណឹង

## ស្តីពី

## សេចក្តីព្រាង សំណើវិសោធនកម្មស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ លេខ ១៩ "ការលាតត្រដាងព័ត៌មានក្រុមហ៊ុនបុត្រសម្ព័ន្ធដែលមិនមានការទទួលខុសត្រូវសាធារណៈ"

និយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**) សូមជម្រាបជូនដំណឹងដល់គ្រប់សហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញ គណនេយ្យករ សវនករ និងសាធារណជនទូទៅ ឱ្យបានជ្រាបថា៖ នាថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៤ ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standards Board) ដែលជាស្ថាប័នឯករាជ្យក្នុងការអភិវឌ្ឍ និង អនុម័តលើស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ បានចេញផ្សាយសេចក្តីព្រាងសំណើវិសោធនកម្មលើស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ (IFRS) លេខ ១៩៖ ការលាតត្រដាងព័ត៌មានក្រុមហ៊ុនបុត្រសម្ព័ន្ធដែលមិនមានការទទួលខុសត្រូវសាធារណៈ (Exposure Draft – Amendments to IFRS 19 – Subsidiaries without Public Accountability: Disclosure) ដូចមានភ្ជាប់ជូនខាងក្រោម។

សំណើផ្តល់មតិយោបល់ទៅលើសំណើវិសោធនកម្មនេះ នឹងផុតកំណត់ត្រឹមចុងខែវិច្ឆិកា ឆ្នាំ២០២៤។ ដូច្នេះ ប្រសិនបើ សហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញ គណនេយ្យករ សវនករ និងសាធារណជនទូទៅមានបំណងក្នុងការបញ្ចេញមតិយោបល់លើសេចក្តីព្រាងនេះ សូមផ្ញើមតិយោបល់មក **ន.គ.ស.** តាមរយៈអ៊ីម៉ែល៖ l.dane@acar.gov.kh យ៉ាងយូរត្រឹមថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៤។

សម្រាប់ព័ត៌មានលម្អិត សូមចូលទៅកាន់គេហទំព័ររបស់និយ័តករ : www.acar.gov.kh។

អាស្រ័យហេតុនេះ សូម សហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញ គណនេយ្យករ សវនករ និងសាធារណជន ទូទៅដែលមានតម្រូវការប្រើស្តង់ដាគណនេយ្យអន្តរជាតិខាងលើនេះ ជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កញ្ញា គ.ស.២០២៤

**និយ័តករគណនេយ្យនិងសវនកម្ម**

សូមស្កេន QR Code ដើម្បីទាញយកឯកសារ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីម៉ែល : info@acar.gov.kh
ទូរស័ព្ទ ០៩៥ - ២៣ ៨៨២ ១១១
Phone: 023 882 111